ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
## ស្តីពី
## សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## ប្រចាំខែកក្កដា ឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត

### I- សភាពការណ៍រួម

នៅក្នុងខែកក្កដា ឆ្នាំ២០១៦នេះ តាមការកត់សម្គាល់ឃើញថា មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយល្អបង្គួរនៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេស។ ប្រជាកសិករបានខិតខំជំរុញការងារបង្កបង្កើនផលស្រូវរដូវវស្សាយ៉ាងសស្រាក់សស្រាំ ដោយសម្រេចបាន ៧៦,៧០% គិតមកទល់ចុងខែកក្កដា ឆ្នាំ២០១៦នេះ។ ស្ទូងនិងព្រោះអនុវត្តបាន ១ ៨៩៩ ៣៣៦ហ.ត នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត មានសភាពលឿនជាងឆ្នាំមុនចំនួន ៣៤២ ១៦៨ហ.ត ស្មើនឹង ១៦,០៤% បើប្រៀបធៀបរយៈពេលដូចគ្នា។ ប្រជាកសិករបាននិងកំពុងបន្តខិតខំជំរុញការរៀបចំដី ភ្ជួររាស់ សាបព្រោះ និងដកស្ទូង ដើម្បីឱ្យទាន់រដូវកាលដាំដុះ ដោយអនុវត្តបច្ចេកទេសកសិកម្មសមស្រប។ ជាការកត់សម្គាល់ ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មកំពុងមាននិន្នាការកើនឡើងដែលជាបច្ច័យមួយបង្ហាញអំពីដំណើរការវិវឌ្ឍន៍នៃយន្តូបនីយកម្មកសិកម្ម។ ក្រៅពីដំណាំស្រូវ ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម ក៏មានការកើនឡើងដែរបើប្រៀបធៀបនឹងឆ្នាំមុន។ មកដល់ពេលនេះ កសិករបានប្រមូលផលស្រូវស្រាលដើមរដូវវស្សាជាបណ្តើរៗហើយ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ដែលសម្រេចបានសម្រាប់ខែកក្កដា ឆ្នាំ២០១៦នេះ មានដូចខាងក្រោម៖

### II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

#### ១ ផ្នែកដាំដុះ

##### ១.១ ផលិតកម្មដំណាំស្រូវ

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៦ គិតត្រឹមថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៤១០ ៥៩២ហ.ត ក្នុងនោះភ្ជួររាស់ដោយគោក្របីមានចំនួន ១៨៩ ៦២៩ហ.ត និងដោយគ្រឿងយន្តមានចំនួន ២ ២២០ ៩៦៣ហ.ត លើសឆ្នាំមុនចំនួន ៣៣៩ ០៦៧ហ.ត គិតក្នុងរយៈពេលដូចគ្នា
- ផ្ទៃដីសាបសម្រេចបានចំនួន ៤៤ ៣៩០ហ.ត តិចជាងឆ្នាំមុនចំនួន ១ ០៤៧ហ.ត
- ផ្ទៃដីសន្ទូង និងពង្រោះសម្រេចបានចំនួន ១ ៨៩៩ ៣៣៦ហ.ត ស្មើនឹង ៧៦,៧០% នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុនចំនួន ៣៤២ ១៦៨ហ.ត និងស្រូវតាមប្រភេទរួមមាន៖

  -ស្រូវស្រាលចំនួន ៤៦៨ ៣៦៤ហ.ត លើសឆ្នាំមុនចំនួន ៧៩ ១៥៣ហ.ត



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

-ស្រូវកណ្តាលចំនួន ៩២០ ៨៣៨ហ.ត លើសឆ្នាំមុនចំនួន ១៩៨ ៨៨៦ហ.ត

-ស្រូវធ្ងន់ចំនួន ៤៤២ ៣១៤ហ.ត លើសឆ្នាំមុនចំនួន ៧៤ ២២២ហ.ត

-ស្រូវចម្ការចំនួន ២៧ ៦១៤ហ.ត តិចជាងឆ្នាំមុនចំនួន ៤ ៥០១ហ.ត

-ស្រូវឡើងទឹកចំនួន ៤០ ២០៦ហ.ត តិចជាងឆ្នាំមុនចំនួន ៥ ៥៩២ហ.ត។

មកដល់ពេលនេះ កសិករបានប្រមូលផលស្រូវស្រាលដើមរដូវវស្សាជាបណ្តើរៗហើយលើផ្ទៃដី ២៣ ៧៩០ហ.ត ទទួលបានទិន្នផលជាមធ្យម ៤,១៣៧តោន/ហ.ត បរិមាណផលសរុប ៩៨ ៤១៩តោន។

### ១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៨០៨ ២៣៦ហ.ត លើសឆ្នាំមុនចំនួន ៦៥ ៤៣១ហ.ត ក្នុងនោះ៖

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៧៥៥ ៤៧៦ហ.ត ស្មើនឹង ១២២,៦២% នៃផែនការ ៦១៦ ១២៣ហ.ត លើសឆ្នាំមុនចំនួន ៩៧ ២៤៩ហ.ត

- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៥២ ៧៦០ហ.ត ស្មើនឹង ៣៨,៤៤% នៃផែនការ ១៣៧ ២៣៨ហ.ត តិចជាងឆ្នាំមុនចំនួន ៣១ ៨១៨ហ.ត។

### ១.៣ ការនាំចេញអង្ករ

ការនាំចេញអង្ករកម្ពុជារយៈពេល៧ខែដើមឆ្នាំ២០១៦នេះ មានបរិមាណចំនួន ២៩២ ២៧៧តោនដែលមានការថយចុះចំនួន ២០ ០៤០តោន (-៦,៩%) តិចជាងបរិមាណនាំចេញរយៈពេល៧ខែដើមឆ្នាំ២០១៥ ដែលមានចំនួន ៣១២ ៣១៧តោន។ ក្នុងនោះបរិមាណនាំចេញក្នុងខែកក្កដា នេះមានចំនួន ២៤ ០៨៧តោន ដែលមានការថយចុះចំនួន ៤ ៤០៥តោន (-១៨,៣%) តិចជាងខែកក្កដា ឆ្នាំ២០១៥ និងបាននាំចេញទៅកាន់ទិសដៅចំនួន ៥៨ប្រទេស ក្នុងនោះ ប្រទេសចិនឈរលំដាប់ទី១ (៤៨ ៨២៥តោន) ប្រទេសបារាំងឈរលំដាប់ទី២ (៤២ ៨៣៩តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (៤០ ២២៩តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤ (១៥ ៨៤៣តោន) ប្រទេសបែលហ្សិកឈរលំដាប់ទី៥ (១៥ ៦៣៣តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៦ (១៥ ៤៧៧តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៧ (១៤ ៥៦៥តោន) ប្រទេសឆេកឈរលំដាប់ទី៨ (១២ ៦១៦តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៩ (១១ ៤៤៧តោន) និង ប្រទេសហុងគ្រីឈរលំដាប់ទី១០ (៨ ៧៣៩តោន)។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥០៨ | ៧៥៨ | ៣៩០ | - |
| សរុប I | | ៥០៨ | ៧៥៨ | ៣៩០ | - |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុគន្ធីកា អិនវេសមេន គ្រុប | ១២ ៦០៣ | ១៦ ០២៨ | ៦ ៨២៩ | - |
| ២ | ក្រុមហ៊ុន ស៊ីហ្វារ៉ាប់ប៊ើលីមីធីត (រតនគីរី) | ៧៩ | ២ ៤៩៨ | ២៩ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ៩៩០ | ២ ១០១ | ៤៥៤ | - |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ៣ ១១០ | ៥ ៦៣៣ | ១ ៥៥៦ | - |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣ ៩៩៧ | ៨ ៦៦១ | ១ ៤៧០ | - |
| ៦ | ក្រុមហ៊ុន ស៊ីហ្វវីសសស់ (ស្នួល) | ១ ៧៤៥ | ៤ ៣៦៥ | ៧២៩ | - |

| | | | | | |
|---|---|---|---|---|---|
| ៧ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង រមាសហែក) | ១ ៨៨២ | ៣ ៣៩០ | ២៤៣ | - |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៣២៧ | ៥ ៩២៤ | ៣៨៨ | - |
| ៩ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៤ ០៣៥ | ៥ ៧៣១ | ១ ៧៩៨ | - |
| សរុប II | | ៣១ ៧៦៨ | ៥៤ ៣៣១ | ១៣ ៨៨៦ | - |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៥ ៧៣៥ | ១៨៤ ២៥២ | ៣ ៤៩៥ | ៥១៦ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៧៦ ៤៩៦ | ១៤៩ ៨៥៣ | ៤៣ ២៧២ | ៧ ៣៧៥ |
| សរុប III | | ៨២ ២៣១ | ៣៣៤ ១០៥ | ៤៦ ៧៦៧ | ៧ ៨៩១ |
| សរុប I+II+III | | ១១៤ ៥០៧ | ៣៨៩ ១៩៤ | ៦០ ៦៥៣ | ៧ ៨៩១ |

- គួរកត់សម្គាល់ថា សម្រាប់ខែកក្កដា ឆ្នាំ២០១៦នេះ តម្លៃកៅស៊ូជាមធ្យមក្នុងរង្វង់ ១ ២០៩ដុល្លារក្នុងមួយតោន។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានវាស់ទំហំដើមកៅស៊ូក្នុងឡូត៍ពិសោធន៍ក្លូន SRAA01 នៅក្រុមហ៊ុនក្រែកខេមបូឌា ស្រុកស្វាយលើ ខេត្តសៀមរាប
- ធ្វើតេស្តភាគសំណាកយថាប្រភេទចំនួន ២៥ភាគសំណាក សម្រាប់ធ្វើតេស្តត្រួតពិនិត្យគុណភាពរបស់រោងចក្រកែច្នៃកៅស៊ូ និងនិស្សិតកម្មសិក្សា
- ត្រួតពិនិត្យពាក្យស្នើសុំចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍យថាប្រភេទ និងរៀបចំលិខិតជូនដំណឹងអំពីការត្រួតពិនិត្យលើកដំបូងដោយផ្ទាល់
- រៀបចំអត្ថបទស្រាវជ្រាវឥទ្ធិពលអ៊ីដ្រុកស៊ីលអាមីនស៊ុលផាតណឹតលើការធ្វើវុលកាវីសាស្យុងកៅស៊ូសន្លឹក
- រៀបចំថ្នាលកៅស៊ូបណ្តុះកូនកៅស៊ូឆ្នាំ២០១៦-២០១៧
- វិភាគ DRC ចំនួន០២ដងលើ១៤ចម្ការពិសោធន៍ និងវិភាគស្តង់ដារ LD ចំនួន ០១ដង
- ចុះប្រមូលទិន្នន័យនិងលាបថ្នាំរំញោចចម្ការពិសោធន៍កៅស៊ូក្រែក ខេត្តត្បូងឃ្មុំ
- លាបថ្នាំរំញោចចំនួន ៩ចម្ការពិសោធន៍ និងវាស់ទឹកជ័រតាមចម្ការពិសោធន៍នីមួយៗ
- បណ្តុះបណ្តាលនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាលាជាតិកសិកម្មព្រែកលៀប។

## ៣ ផ្នែកផលិតកម្ម និងបសុព្យាបាល

**៣.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងកំពុងរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្ត និងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

- **ការងារកែលម្អពូជ៖** ប្រជាកសិករភាគច្រើនកាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាពមានការលូតលាស់ឆាប់រហ័សធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។
- **ការងារឡជីវឧស្ម័ន៖** ដោយមានការអភិវឌ្ឍផ្នែកចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននឹងកំពុងអនុវត្តយ៉ាងសកម្មដែលមកទល់ពេលនេះខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង



10/Aug/2016

តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់សម្រេចបាន ១១៧ឡ និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបាន ២៥០ឡ។

- **ចំណីសត្វ៖** បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។
- **ការងារដំណាំចំណីសត្វ៖** តាមបណ្តាខេត្តមួយចំនួនបានធ្វើសួនដំណាំចំណីសត្វ ធ្វើការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការបន្តជាមួយគម្រោង CIAT និង EU ។

## ៣.២ ការងារបសុព្យាបាល

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖**

រាជធានី-ខេត្តចំនួន ១៧ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ២ ៧៦២លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយក្រុមអន្តរាគមន៍របស់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ព្រមទាំងបានកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន ១៣៦,៥គីឡូក្រាម និងផាកពិន័យជាទឹកប្រាក់បានចំនួន ១លានរៀល ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនជ្រូករស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញ ដើម្បីការពារការឆ្លងរាលដាលនៃជំងឺជ្រូកត្រចៀកខៀវមកពីខេត្តជិតខាង។

- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យជាប្រចាំលើទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តាខេត្ត-រាជធានី និងចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស។
- ស្ថិតិសត្តឃាតដ្ឋានដែលទទួលបានការអនុញ្ញាតនៅទូទាំងប្រទេសសរុបចំនួន ១៤២កន្លែង ដូចមានតារាងខាងក្រោម៖

| ល.រ | ឈ្មោះរាជធានី-ខេត្ត | ចំនួនសត្តឃាតដ្ឋាន | | ចំនួនសត្វពិឃាត | | | |
|---|---|---|---|---|---|---|---|
| | | សត្តឃាតដ្ឋានស្របច្បាប់ | ពិឃាតប្រមូលផ្តុំ/ពិឃាតតាមផ្ទះ | គោ (ក្បាល) | ក្របី (ក្បាល) | ជ្រូក (ក្បាល) | មាន់ (ក្បាល) |
| ១ | ភ្នំពេញ | ១១ | | | | | |
| ២ | កណ្តាល | ២២ | | ៤៣៣ | | ៣ ៨៣៤ | ៦១ ៣៤០ |
| ៣ | កំពង់ស្ពឺ | ១១ | | ៦៤៤ | | ២ ៩២០ | |
| ៤ | ព្រៃវែង | ១២ | | ៣២៩ | ៣ | ៣ ១៣៣ | |
| ៥ | ស្វាយរៀង | ០៨ | | ១ ០៧៣ | | ៨ ៨៧២ | |
| ៦ | កំពង់ឆ្នាំង | ១០ | | | | | |
| ៧ | ពោធិ៍សាត់ | ០៦ | | ២៣៣ | ១៣ | ១ ៨៦៦ | |
| ៨ | បាត់ដំបង | ១៤ | | ១ ៤៣៣ | ៣១ | ៦ ០៩៧ | |
| ៩ | បន្ទាយមានជ័យ | ១០ | | ៣ ៣១៨ | | ១៩ ៨៩០ | ១២ ៩១៦ |
| ១០ | សៀមរាប | ៧ | | ៦៩០ | ១៥ | ៤ ១៦៦ | |
| ១១ | កំពង់ធំ | ៦ | | ៤ ០៦៤ | ៤១២ | ១៦ ៥៤៨ | |
| ១២ | ព្រះសីហនុ | ៣ | | ៨៥ | ៤ | ៨៩៥ | |
| ១៣ | កែប | ១ | | | | | |



10/Aug/2016

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៤ | កំពត | ៥ | | | | | |
| ១៥ | កោះកុង | ៣ | | | | | |
| ១៦ | ក្រចេះ | ៥ | | ៤៦០ | ១៤ | ២ ៧៥៤ | |
| ១៧ | ស្ទឹងត្រែង | ១ | | ៩៦ | ៥៩ | ៩៥៩ | |
| ១៨ | រតនគិរី | ៣ | | ១៤៩ | ៨២ | ៩៧៦ | |
| ១៩ | មណ្ឌលគិរី | ២ | | ១២៧ | | ៤២០ | |
| ២០ | ប៉ៃលិន | ១ | | | | | |
| ២១ | ឧត្តរមានជ័យ | ១ | | ២៣៤ | | ១ ៤០១ | ១ ៣០០ |
| ២២ | តាកែវ | ០ | ១៨ | | | | |
| ២៣ | កំពង់ចាម | ០ | | ៣៦៧ | | ២ ២៧៩ | ១ ៥៧២ |
| ២៤ | ត្បូងឃ្មុំ | ០ | | | | | |
| ២៥ | ព្រះវិហារ | ០ | | | | | |
| | សរុប | ១៤២ | ១៨ | ១៣ ៧៣៥ | ៦៣៣ | ៧៧ ០១០ | ៧៧ ១២៨ |

- **ការងារនីតិកម្មនិងវិវាទៈ** ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ហើយក្រសួងកំពុងរៀបចំបោះពុម្ពផ្សព្វផ្សាយជាសាធារណៈឲ្យបានទូលំទូលាយ និងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់តាមអាទិភាព។

**៣.៣ ការងារស្រាវជ្រាវៈ**

- **ការងារស្រាវជ្រាវបសុព្យាបាលៈ** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី។ ក្នុងខែកក្កដា នេះពិនិត្យវត្ថុវិភាគសរុបបានចំនួន ១ ០៣២វិភាគ។
- **ការងារស្រាវជ្រាវផលិតកម្មៈ** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន ១៥៧ក្បាល ក្នុងនោះគោបាចំនួន ៣ក្បាល គោប្រាម៉ាន់កាត់ចំនួន ៣២ក្បាល គោជំទង់ចំនួន ៣២ក្បាល គោបៅដោះចំនួន ៤៧ក្បាល គោកំជែងសែនចំនួន ៤៣ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុបចំនួន ៣០៤ក្បាល ក្នុងនោះជ្រូកបាចំនួន ៤ក្បាល ជ្រូកមេចំនួន ៦៨ក្បាល កូនជ្រូកចំនួន ១៣៩ក្បាល ជ្រូកត្រៀមលក់ចំនួន ១១ក្បាល កូនជ្រូកលក់ចំនួន ៧០ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតីនិងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

**៣.៤ ការងារផ្សព្វផ្សាយបច្ចេកទេសៈ** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើ

- បានធ្វើការបកស្រាយធនធានគម្របព្រៃឈើតាមរយៈរូបភាពផ្កាយរណប LANDSAT ក្នុងឆ្នាំ២០១៦ សម្រេចបាន១០%

- បានកែសម្រួលលើឯកសារកម្រិតបំភាយយោងការបញ្ចេញឧស្ម័នការបូនិកពីការបាត់បង់ និងរេចរឹលព្រៃឈើ ដើម្បីដាក់ជូនអង្គការសហប្រជាជាតិក្នុងសន្និសីទនៃរដ្ឋភាគីលើកទី២២ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដោយគាំទ្របច្ចេកទេសពីអ្នកជំនាញការ JICA-CAM-REDD និង FAO

- រដ្ឋបាលព្រៃឈើបានអនុម័តផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ៦មានផ្ទៃដីសរុបចំនួន ៤៥៨ហ.ត ក្នុងនោះ ខេត្តពោធិ៍សាត់មានចំនួន ៣សហគមន៍ព្រៃឈើ មានផ្ទៃដីទំហំ ១០២ហ.ត ខេត្តកំពង់ធំចំនួន ២សហគមន៍ព្រៃឈើ មានផ្ទៃដីទំហំ ២៩១ហ.ត និងខេត្តកំពង់ស្ពឺចំនួន ១សហគមន៍ព្រៃឈើ មានផ្ទៃដីទំហំ ៦៥ហ.ត

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើចំនួន៥ករណី ដែលមានឈើហ៊ុបមូលចំនួន ១ ៤០០ម៣ កូនឈើចំនួន ៣៤ ១០០ដើម អុសចម្រុះចំនួន ៥ ៥០០ស្ទែរ ជ័រទឹកចំនួន ២៨០តោន និងជ័រចុងទម្ងន់ ១០តោន

- បានធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើចំនួន ២ក្រុមហ៊ុនគឺក្រុមហ៊ុន សីលាជាម៉ិច នៅខេត្តព្រះវិហារ និងក្រុមហ៊ុន សំអឿនសុវណ្ណ នៅខេត្តព្រះវិហារ។

### ៤.២ ការងារអភិរក្សសត្វព្រៃ

- បានចុះប្រមូលសំណាកសត្វកណ្តុរចំនួន ៤២៧សំណាក ស្មើនឹង ៣៩ក្បាល ដើម្បីធ្វើការវិភាគរកមេរោគ និងជំងឺ ស្ថិតនៅភូមិស្រែធំ ស្រុករវៀង ខេត្តព្រះវិហារ

- បានចុះប្រមូលសំណាកសត្វប្រចៀវ និងជ្រូងចំនួន ១៨៩សំណាក ស្មើនឹង ៦៣ក្បាល ដើម្បីធ្វើការវិភាគរកមេរោគ និងបានធ្វើជំរឿនសត្វជ្រូង និងប្រចៀវដោយរាប់ឃើញចំនួនប្រហែល ៤៥៩៣ក្បាល នៅស្រុកកោះធំ ខេត្តកណ្តាល

- បានផ្តល់ចំណីគោចំនួន ១ក្បាល ដល់ត្មាតនៅខេត្តស្ទឹងត្រែង ក្រចេះ ដោយរាប់ឃើញត្មាតសរុបចំនួន ៣ក្បាល។ ការផ្តល់ចំណីត្មាតគឺដើម្បីធានាការរស់រានរបស់សត្វត្មាត និងធ្វើការអង្កេតតាមដាន

- បានរៀបចំកិច្ចប្រជុំការអប់រំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលជាមួយនឹងប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាចំនួន ២០លើក ដែលមានអ្នកចូលរួមសរុបចំនួន ១ ០៥៦នាក់ ដោយផ្តោតទៅលើការការពារ និងអភិរក្សសត្វស្លាបនៅតាមដងទន្លេមេគង្គក្នុងខេត្តក្រចេះ និងការអភិរក្សសត្វក្តាន់ ក្នុងឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ និងឃុំវឌ្ឍនៈ ស្រុកសំបូរ ខេត្តក្រចេះ

- បានចុះផ្សព្វផ្សាយអំពីការជួញដូរសត្វព្រៃដែលមានអ្នកចូលរួមចំនួន ៦០នាក់ នៅខេត្តព្រះវិហារ។

### ៤.៣ កសិដ្ឋានចិញ្ចឹម ការបង្ក្រាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ខែកក្កដា ឆ្នាំ២០១៦នេះ ការងារនៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាគឺ៖ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន ៩៥ក្បាល សត្វកើតថ្មីចំនួន ១ក្បាល ដោះលែងទៅព្រៃធម្មជាតិវិញចំនួន ១២៣ក្បាល ជួសជុលផ្លូវចំនួន ៤ ២០០ម២ ។ សត្វព្រៃសរុបចំនួន ១ ៣៣៧ក្បាល(បក្សី ៥០ប្រភេទ ថនិកសត្វ ៤៥ប្រភេទ និងល្មូន ១៣ប្រភេទ)

- ក្រុមល្បាតសហគមន៍ចំនួន ២៨នាក់ បន្តការងារល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៥ គឺនៅអារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់) បានប្រទះករណីបទល្មើសចំនួន៤ករណី។

### ៤.៤ ការងារដាំដើមឈើ

- ឈូសឆាយដីបានទំហំ ២៥ហិកតា បណ្តុះកូនឈើបានចំនួន ៧០ ០០០ដើម និងបានដាំកូនឈើជាចម្ការលើផ្ទៃដីទំហំ ៣០ហ.ត នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ

- បានដាំដុះកូនឈើជាចម្ការលើផ្ទៃដីទំហំ ២០ហិកតា នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារទីជម្រាល ក្បាលឆាយ ខេត្តព្រះសីហនុ

- បានដាំដុះកូនឈើជាចម្ការលើផ្ទៃដីទំហំ ៥០ហិកតា នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើខ្នារង្វាស់ ខេត្តសៀមរាប

- បានធ្វើការថែទាំចម្ការឈើ (ឆ្នាំទី១-ឆ្នាំទី៥) មានផ្ទៃដីសរុបទំហំ ២ ១៩៣ហ.ត ស្ថិតនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើទូទាំងប្រទេស និងកំពុងពង្រឹងការយាមល្បាត ដើម្បីទប់ស្កាត់ការកាប់រុករាន ទន្ទ្រាន ហ៊ុមព័ទ្ធ កាន់កាប់ដីព្រៃឈើ និងទប់ស្កាត់ភ្លើងព្រៃ

- បណ្តុះកូនឈើគ្រប់ប្រភេទបានចំនួន ១៦៧ ២០៩ដើម

- ចែកកូនឈើជូនប្រជាពលរដ្ឋបានចំនួន ៣៣១ ៥៤៣ដើម

- បានបណ្តុះកូនផ្ចៀកបានចំនួន ៣០ ០០០ ដើម និងបានធ្វើការអភិរក្សធនធានសេនេទិកតាមរយៈការដាំជាចម្ការពូជ លើផ្ទៃដីទំហំ ១០ហ.ត នៅខេត្តព្រះសីហនុ

- បានបណ្តុះកូនគ្រញូងចំនួន២ ០០០ដើម និងបានដាំបញ្ចូលទៅក្នុងតំបន់ប្រភពគ្រាប់ពូជឈើគ្រញូង ខេត្តសៀមរាប

- បានផ្ទេររុក្ខជាតិពីបន្ទប់បណ្តុះពន្លឺទៅផ្ទះកញ្ចក់គឺ ឈើអង្កាញ់ Cassia siamea Lam. ចំនួន ២ដើម។ កាត់បណ្តុះជាលិកាឈើប្រេងខ្យល់ Eucalyptus pellita F. Muell ចំនួន ១៣ដើម ឈើឥន្ទនេល Lagerstroemia luadonii Teysm. and Binn. ចំនួន ១៨ដើម ឈើអង្កាញ់ Cassia siamea Lam. ចំនួន ៣ដើម បណ្តុះគ្រាប់គ្រញូងចំនួន ១០០គ្រាប់ និងផ្លាស់ប្តូរសារធាតុចិញ្ចឹមកូនប្រទាល Plant grasse collezion estate ចំនួន ១៥០ដើម ដាក់ក្នុងកែវនៅបន្ទប់បណ្តុះពន្លឺ និងផ្លាស់ប្តូរសារធាតុចិញ្ចឹម ដល់អ័រគីដេដែលនៅផ្ទះកញ្ចក់បានចំនួន ៧២ផើង

- បានរៀបចំពិធីរុក្ខទិវា០៩ កក្កដា នៅខេត្តព្រះវិហារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី ដោយបានដាំដើមឈើចម្រុះចំនួន ១១ ៨២៦ដើម លើផ្ទៃដីទំហំ ១២ហ.ត។

### ៤.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញឈើចំនួន ៣ក្រុមហ៊ុន ដែលមានបរិមាណសរុប ១៩ម$^{៣}$

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលឈើចំនួន ២ក្រុមហ៊ុន ដែលមានបរិមាណសរុប ១២១ម$^{៣}$

- ចុះពិនិត្យទីតាំងរោងម៉ាស៊ីនអារ-កែច្នៃឈើតាមលក្ខណៈបច្ចេកទេសដែលមានក្រុមហ៊ុនចំនួន ២ ដែលស្នើសុំបន្តសុពលភាព។

### ៤.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ខែកក្កដា ឆ្នាំ២០១៦នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន ៧៨៥ ៥៧៥ ១១៩រៀល និងចំណូលពីសេវាសាធារណៈចំនួន ៥១៦ ៥១៩ ៧៥២រៀល និង១ ៩១៧,៤៩ដុល្លារអាមេរិក។

### ៤.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែកក្កដា ឆ្នាំ២០១៦នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន ១០៧ករណី ដោយបញ្ជូនទៅតុលាការចំនួន ៦៨ករណី និងពិន័យអន្តរការណ៍ចំនួន ៣៩ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន ២៨ម$^{៣}$ ឈើអារចំនួន ៤ ៨៤០ម$^{៣}$ ឈើក្រាក់គ្រញូងចំនួន ៣៦ម$^{៣}$ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន ៤១៤ក្បាលនិង២ ៨៩៤គ.ក្រ អនុផលព្រៃឈើ និងសម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន ១៧២ហិកតា ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី

- បានចុះពង្រឹងការអនុវត្តច្បាប់ចំនួន ២លើក នៅក្នុងខេត្តកំពង់ធំចំនួន ១លើក និងខេត្តព្រះវិហារចំនួន ១លើក

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រី ការធ្វើអាជីវកម្មត្រូវបានផ្អាកសកម្មភាពចាប់ពីខែមេសារហូតដល់ខែកញ្ញា។ រីឯលទ្ធផលដែលអនុវត្តបានក្នុងរយៈពេល៣ខែដើមឆ្នាំ២០១៦នេះចំនួន ១ ០៥០តោន ស្មើនឹង ៨,៧៥% នៃផែនការ ១២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ២៣៥តោន

- នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន ២១ ២០០តោន សរុបរយៈពេល៧ខែបានចំនួន ១៥៤ ២០០តោន ស្មើនឹង ៤៤,៨៣% នៃផែនការ ៣៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ៣១ ០៥០តោន

- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន ៩ ៦០០តោន សរុបរយៈពេល៧ខែបានចំនួន ៣៨ ១០០តោន ស្មើនឹង ២៦,៤៦% នៃផែនការ ១៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ១៦ ០៥៥តោន។

៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៩ ២៥០តោន សរុបរយៈពេល៧ខែបានចំនួន ៦៤ ៦០០តោន ស្មើនឹង ៥៨,៧៣% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៤ ៦០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន ២៣ ៦០០តោន សរុបរយៈពេល៧ខែបានចំនួន ៩២ ៦៥០តោន ស្មើនឹង ៥៣,៦២% នៃផែនការ ១៧២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ១៣ ៦០០តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន ៤២ ០០០ក្បាល សរុបរយៈពេល៧ខែបានចំនួន ១៥៧ ០០០ក្បាល ស្មើនឹង ៦២,៨០% នៃផែនការ ២៥០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ១ ៥០០ក្បាល

- ការភ្ញាស់កូនត្រីពូជ អនុវត្តបានចំនួនប្រមាណ ៤៧ ០០០ ០០០កូន សរុបរយៈពេល៧ខែបានចំនួន ១០៧ ០០០ ០០០កូន ស្មើនឹង ៥៩,៤៤% នៃផែនការ ១៨០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួនប្រមាណ ២ ០០០ ០០០កូន

- កិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំទិវាមច្ឆជាតិ ១ កក្កដា ឆ្នាំ២០១៦ នៅខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាប អនុវត្តបានចំនួន ៧ ០០០តោន សរុបរយៈពេល៧ខែបានចំនួន ៣៣ ២០០តោន ស្មើនឹង ៤០,៤៩% នៃផែនការ ៨២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ៤ ៣០០តោន

- ផលនេសាទសមុទ្រ អនុវត្តបានចំនួន ៨០០តោន សរុបរយៈពេល៧ខែបានចំនួន ៦ ៦២៥តោន ស្មើនឹង ៨២,៨១% នៃផែនការ ៨ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៣២៥តោន

- ការផលិតទឹកត្រី អនុវត្តបានចំនួន ៤ ០០០ ០០០លីត្រ សរុបរយៈពេល៧ខែបានចំនួន ៣៧ ០០០ ០០០លីត្រ ស្មើនឹង ៧៤,០០% នៃផែនការ ៥០ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ៦ ០០០ ០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ អនុវត្តបានចំនួន ៨៥០តោន សរុបរយៈពេល៧ខែបានចំនួន ៥ ៩០០តោន ស្មើនឹង ៣៩,៣៣% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ២០០តោន

- ផលនេសាទកែច្នៃ អនុវត្តបានចំនួន ៤០០តោន សរុបរយៈពេល៧ខែបានចំនួន ៣ ២០០តោន ស្មើនឹង ៦៤,០០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ១០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- សម្រាប់ខែកក្កដា ឆ្នាំ២០១៦នេះ សំណុំរឿងបទល្មើសជលផលមានចំនួន ៣៦៣ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ៣៣៣ករណី និងសមុទ្រចំនួន ៣០ករណី

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង ១០៧ ៦៩៩ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន ៩ ៨៥៥មាត់ បង្គោល/ចម្រឹងចំនួន ៤១ ៥៦០ដើម ឧបករណ៍ឆក់ត្រីចំនួន ៣០គ្រឿង សម្រាស់ចំនួន ៩០០ម៉ែត្រក្រឡា និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន ៣ ២៩១គ.ក្រ

- ចាប់ពីដើមឆ្នាំ២០១៦នេះ បានផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន ៩៤វគ្គ ដោយមានអ្នកចូលរួមចំនួន ៣ ៧៤២នាក់ ក្នុងនោះស្ត្រីចំនួន ៧២០នាក់។ ក្នុងខែកក្កដា ឆ្នាំ២០១៦នេះ អនុវត្តបាន ០៩វគ្គ ដោយមានអ្នកចូលរួមចំនួន ២៥០នាក់

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យ និងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព និងចាត់វិធានការទប់ស្កាត់និងបង្ក្រាបបទល្មើសជលផលក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត។

### ៥.៦ ការប្រមូលចំណូល

- ចំណូលពីវិស័យជលផល សម្រាប់ខែកក្កដា ឆ្នាំ២០១៦ ចំនួន ២០៥ ៩៦៤ ៣៤០រៀល សរុបរយៈពេល ៧ខែបានចំនួន ១ ១៥៨ ៤៤៤ ៦៨០រៀល ស្មើនឹង ៣៨,៦១% នៃផែនការ ៣ ០០០ ០០០ ០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ៩៥៨ ៤០៥ ០៩៥រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានចុះពិនិត្យការផលិតគ្រាប់ពូជស្រូវ នៅខេត្តកំពង់ស្ពឺ កំពង់ធំ និងបាត់ដំបង
- បានចុះធ្វើការសិក្សាស្រាវជ្រាវពីខ្សែចង្វាក់ផ្គត់ផ្គង់ដំណាំបន្លែ នៅខេត្តសៀមរាប
- បានចុះប្រមូលទិន្នន័យស្តីពីការទទួលយកពូជស្រូវទាំង១០ពូជ ដែលបញ្ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខេត្តសៀមរាប
- បានចុះត្រួតពិនិត្យស្រែបង្ហាញ និងការងារពិសោធន៍ នៅខេត្តបាត់ដំបង និងតាកែវ
- បានចុះរៀបចំពិសោធន៍ ចែកពូជ និងសម្ភារពិសោធន៍ នៅខេត្តកំពង់ចាម កំពង់ស្ពឺ កំពត និងព្រៃវែង
- បានចុះជ្រើសរើសទីកន្លែងពិសោធន៍ និងចែកពូជ សម្ភារសម្រាប់ការធ្វើស្រែពិសោធន៍បង្ហាញ នៅខេត្តព្រៃវែង ស្វាយរៀង កំពង់ចាម និងខេត្តក្រចេះ
- បានចុះធ្វើការដាំដុះដំណាំស្រូវពិសោធន៍បង្ហាញ នៅខេត្តតាកែវ និងកំពត
- បានចុះអនុវត្តការងារពិសោធន៍ស្រាវជ្រាវ នៅខេត្តបាត់ដំបង សៀមរាប កំពង់ធំ និងកំពង់ចាម។

## ៧ ផ្នែកនីតិកម្មកសិកម្ម

### ៧.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន ២២ក្រុមហ៊ុន សរុបចំនួន ៤៣១មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ១៨ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មចំនួន ០៦ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ០៣ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ០១ក្រុមហ៊ុន។

### ៧.២ ការងារមន្ទីរពិសោធន៍

- ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជិកាចំនួន ១១ក្រុមហ៊ុន សរុបចំនួន ៩៧សំណាក។

### ៧.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម ជូនដល់មន្ទីរកសិកម្មខេត្តកំពង់ចាម និងខេត្តព្រៃវែង

- បានសហការជាមួយមន្ទីរខេត្តកំពង់ចាម រៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ និងធ្វើជាគ្រូឧទ្ទេសនាមដល់អាជីវករជាអ្នកលក់ដុំ លក់រាយសម្ភារកសិកម្ម នៅខេត្តកំពង់ចាមចំនួន ១៨៦នាក់។

### ៧.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យការនាំចូលរបស់ក្រុមហ៊ុនដែលបានប្រកាសប្រតិវេទន៍អំពីការនាំចូល និងស្នើសុំចុះបញ្ជិកាឃ្លាំងសន្និធិជីកសិកម្ម និងថ្នាំកសិកម្មចំនួន ០៦ក្រុមហ៊ុន និង ០៦ករណី

- បានចុះត្រួតពិនិត្យការនាំចូលរបស់ក្រុមហ៊ុន ដែលបានប្រកាសប្រតិវេទន៍អំពីការនាំចូលថ្នាំកសិកម្ម ជីកសិកម្ម បសុឱសថ ចំណីសត្វ ចំណីបន្ថែម

- ពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១៥ ០០០ ០០០រៀល ពីក្រុមហ៊ុនចំនួន ០៦។

## ៨ ផ្នែករដ្ឋបាល

- ក្នុងខែកក្កដា ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា បានចំនួន ៣៣២ច្បាប់ សរុបចំនួន ២ ៩៩៩ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣៤៧ច្បាប់ សរុបចំនួន ២ ៣២០ច្បាប់ និងទទួលពីរាជធានី-ខេត្តចំនួន ១៤៦ច្បាប់ សរុបចំនួន ៨៣៦ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅក្រសួង ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៩៩៦ច្បាប់ សរុបចំនួន ៦ ១៩៣ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៨៣ច្បាប់ សរុបចំនួន ៤៨៦ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទចំនួន ១៨ច្បាប់ សរុបចំនួន ២៣៧ច្បាប់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការ ការរៀបចំពិធីបុណ្យផ្សេងៗ និងការងារសន្តិសុខរួមរបស់ក្រសួង។

## ៩ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៦ ៦៤៨នាក់ នារីចំនួន ១ ៣៩៨នាក់ ស្មើនឹង ២១% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ៤ ០៤១នាក់ ក្នុងនោះនារីចំនួន ៨១៤នាក់ ស្មើនឹង ២០%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន ២ ៦០៧នាក់ ក្នុងនោះនារីចំនួន ៥៨៤នាក់ ស្មើនឹង ២២%

- ចេញប្រកាសលុបឈ្មោះមន្ត្រីមរណភាពចេញពីក្របខ័ណ្ឌមានចំនួន ០១នាក់

- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងមានចំនួន ០៥នាក់ ផ្ទេរចូលក្រសួងមានចំនួន ០២នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន ០១នាក់

- បានរៀបចំការប្រឡងជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី ដែលក្រសួងមុខងារសាធារណៈបែងចែកឱ្យមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានចំនួន ៣៣៣នាក់

- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកពីការងារចំនួន ១៣នាក់ ក្នុងនោះឈប់សម្រាកប្រចាំឆ្នាំចំនួន ០៨នាក់ (ស្រី ០៥នាក់)ព្យាបាលជំងឺចំនួន ០២នាក់ និងសម្រាកលំហែមាតុភាពចំនួន ០៣នាក់

- ផ្តល់និត្យានុកូលភាពជូនមន្ត្រីកសិកម្មចំនួន ០១ខេត្ត មានចំនួន ០១នាក់

- បានធ្វើផែនការក្របខ័ណ្ឌ២០១៦-២០១៧ ជូនក្រសួងមុខងារសារធារណៈ

- បានចុះតាមដាននិងត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងមន្ត្រីកសិកម្មរាជធានី-ខេត្តលើ ០៣តំបន់

- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ១០ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានសម្របសម្រួលលិខិតទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីវឌ្ឍនភាពនៃការអនុវត្តកំណត់ហេតុប្រជុំ JC កម្ពុជា-វៀតណាមលើកទី១៤

- បានសម្របសម្រួលលិខិតទៅក្រសួងផែនការ ពាក់ព័ន្ធសេចក្តីព្រាង កិច្ចព្រមព្រៀងរួមនៃការតភ្ជាប់សេដ្ឋកិច្ចរវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម

- បានសហការរៀបចំគម្រោងកិច្ចសហប្រតិបត្តិការរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រទេសស្វីស

- បានសម្របសម្រួលលិខិតទៅ MAFIC អំពីសំណើសុំអន្តរាគមន៍ទៅស្ថានទូតឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជាពិនិត្យ និងគាំទ្រសំណើសុំអនុវត្តគម្រោងចំនួន១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានរៀបចំលិខិតទៅ MAFIC ករណីសេចក្តីព្រាងអនុស្សរណៈយោគយល់ស្តីពីលទ្ធកម្មនៃផលិតផលកសិកម្មរវាងកម្ពុជា និងរុស្ស៊ី

- បានសហការជាមួយក្រសួងពាណិជ្ជកម្ម អំពីសំណើសុំផ្តល់យោបល់លើសេចក្តីព្រាងឯកសារគោលគំនិត ស្តីពីការតភ្ជាប់អាស៊ានសហរដ្ឋអាមេរិក

- បានរៀបចំពិធីរំឭកខួបគម្រប់៣០ឆ្នាំ នៃភាពជាដៃគូនិងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ(IRRI) ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី ប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**

- បានសម្របសម្រួល រាល់កិច្ចការទំនាក់ទំនងក្នុង និងក្រៅប្រទេសដើម្បីជូនថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទក្រសួងបានទៅចូលរួមបេសកកម្ម សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានានៅក្រៅប្រទេស រួមទាំងការទទួលជួបសវនាការថ្នាក់ដឹកនាំជាមួយអង្គទូត និងដៃគូអភិវឌ្ឍន៍នានាផងដែរ។

## ១១ ការខារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១១.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦ សរុបចំនួន ១ ០២៣នាក់ (ស្ត្រី ៣៥៦នាក់) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាចំនួន ៧៥៤នាក់(ស្ត្រី ២៨២នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន ២៦៩នាក់(ស្ត្រី ៧៤នាក់)។ សាលាបានកែសម្រួលសារណារបស់និស្សិតចប់ជាស្ថាពរ និងត្រៀមរៀបចំពិធីការពារនៅដើមខែសីហា ឆ្នាំនេះ។ សាលាបានបើកសិក្ខាសាលាដើម្បីពិនិត្យ និងកែលម្អវិធីសិក្សានៅខែកក្កដា និងបូកសរុបបញ្ចប់ការងារក្នុងខែកញ្ញាខាងមុខ។ លើសពីនេះ បានទទួលក្រុមការងារទ្រព្យរដ្ឋ សវកម្មផ្ទៃក្នុង និងសវនកម្មរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានចុះមកធ្វើអធិការកិច្ចហិរញ្ញវត្ថុឆ្នាំ២០១៥។ ទន្ទឹមនឹងនេះ សាលាបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការប្រើប្រាស់ ថែទាំ និងជួសជុលគ្រឿងយន្តកសិកម្មរបស់ជំនាញការជប៉ុន និងបន្តរៀបចំពិសោធន៍ដំណាំស្រូវជប៉ុន និងដំឡូងជ្វា។

### ១១.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥-២០១៦ សរុបមានចំនួន ៩០៨នាក់(ស្ត្រី ៣៧០នាក់) រួមមាន៖

- និស្សិតអាហារូបករណ៍សរុប ៨៥៩នាក់ (ស្ត្រី ៣៥៤នាក់) ក្នុងនោះថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មចំនួន ៤៥៥នាក់(ស្ត្រី ១៧៨នាក់) និងថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មចំនួន ១២៥នាក់(ស្ត្រី ៥១នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃចំនួន ៤៩នាក់ (ស្ត្រី ១៦នាក់) ថ្នាក់បរិញ្ញាបត្រចំនួន ៣៨នាក់(ស្ត្រី ១៥នាក់) និងថ្នាក់បរិញ្ញាបត្ររងចំនួន ១១នាក់ (ស្ត្រី ១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រ

ជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកជំនួយ ក្នុងនោះកំពុងសហការជាមួយអង្គការពេទ្យសត្វគ្មានព្រំដែនដើម្បីរៀបចំមន្ទីរពិសោធន៍សត្វ និងបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍។ សាលាបានសហការជាមួយអង្គការOISCA បញ្ជូននិស្សិតជំនាញក្សេត្រសាស្ត្រចំនួន ០១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល ១ឆ្នាំនៅប្រទេសជប៉ុន ព្រមទាំងជាមួយទីភ្នាក់ងារKOICA ដើម្បីផ្តល់អាហារូបករណ៍សម្រាប់សាស្ត្រាចារ្យ ០១រូប ទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិត នៅប្រទេសកូរ៉េ។ បានទទួលជួបតំណាង JICA ពិភាក្សាពីគម្រោងកសិកម្មសរីរាង្គ និងកំពុងព្រាងគម្រោងស្រាវជ្រាវ។ បានសហការជាមួយ DTRA (Defence Threat Reduction Agency) បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីជំនាញវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វចំនួន ២០រូប ដែលមកពីតាមបណ្តាខេត្តស្តីពី ការអនុវត្តអេពីដេមីសាស្ត្របសុព្យាបាល ជំនាន់ទី៣។

### ១១.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥ សរុបមានចំនួន ៣ ៩២៤នាក់(ស្រី ១ ១៨៧នាក់) ចែកចេញជា១០ មហាវិទ្យាល័យគឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងថ្នាក់ក្រោយឧត្តម ដើម្បីបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ ក្នុងខែកក្កដានេះ សាកលវិទ្យាល័យបានបញ្ជូននិស្សិតចុះធ្វើទស្សនកិច្ចសិក្សា និងធ្វើកម្មសិក្សាអនុវត្តន៍ជាក់ស្តែងនៅតាមសហគមន៍និងមូលដ្ឋានផលិតកម្មនានា ក្នុងខេត្តសៀមរាប មណ្ឌលគិរី តាកែវ កំពត កែប កំពង់សោម និង កំពង់ចាម។ លើសពីនេះ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានទទួលនិស្សិតមកពីជប៉ុន កូរ៉េ និងសាកលវិទ្យាល័យក្នុងតំបន់អាស៊ាន សរុបចំនួន ៧២នាក់ មកបំពេញកម្មសិក្សារួមជាមួយនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម នៅក្នុងខេត្តតាកែវ កំពង់ឆ្នាំង និងកំពង់ចាម ព្រមទាំងបានបញ្ជូនសាស្ត្រាចារ្យនិងនិស្សិតចំនួន ១៣នាក់ ទៅបណ្តុះបណ្តាលវគ្គខ្លីនៅប្រទេសហ្វីលីពីន និងជប៉ុន។ ទន្ទឹមនឹងនេះ សាកលវិទ្យាល័យបានចុះអនុស្សរណៈយោគយល់ លើកិច្ចសហប្រតិបត្តិការរួមជាមួយសាកលវិទ្យាល័យហុកកៃដូ ប្រទេសជប៉ុន។ ដោយមានការឧបត្ថម្ភគាំទ្រពីសមាជិកសភាមណ្ឌលភ្នំពេញ និងជាអនុប្រធានកាកបាទក្រហមរាជធានីភ្នំពេញ សាកលវិទ្យាល័យបានប្រារព្ធធ្វើពិធី ភ្នែកភ្លឺល្អ កាត់បន្ថយគ្រោះថ្នាក់ចរាចរ ដោយកាត់វ៉ែនតាបញ្ចុះតម្លៃជូនដល់និស្សិតចំនួន ១០០០ វ៉ែនតា។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

តាមការកត់សម្គាល់ឃើញថា មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយជាបង្គួរនៅតាម បណ្តាខេត្ត-រាជធានីទូទាំងប្រទេស។ រីឯស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ សម្រេចបាន ៧៦,៧០% លឿនជាងឆ្នាំមុន ៣៤២ ១៦៨ហ.ត (ស្មើនឹង ១៦,០៤%) បើប្រៀបធៀបរយៈពេលដូចគ្នា។ ជារួម ស្ថិតក្នុងបរិការណ៍នេះ ក្រសួងបានដាក់ចេញជាវិធានការជំរុញការងារបង្កបង្កើនផលស្រូវវស្សាឆ្នាំ២០១៦នេះ ដើម្បីណែនាំដល់អង្គភាពក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្តទាំងអស់ឱ្យយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវវស្សាតាមរយៈការផ្តល់អនុសាសន៍ដល់កសិករឱ្យអនុវត្តផលិតកម្មដំណាំស្រូវតាមលក្ខណៈប្រពលវប្បកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ដោយពិចារណាទៅលើយន្តការនិងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងករណីមានការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗដោយថាហេតុ។ ទន្ទឹមនឹងនេះ ក៏បានជំរុញចាត់វិធានការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាព ព្រមទាំងជំរុញការជីកស្តារស្រះ ប្រឡាយ អាងស្តុកទឹក រក្សាទឹកទុកបង្ការការខ្វះខាតនៅចុងរដូវ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើនិងជលផល

តាមគ្រប់រូបភាព ពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តរៀបចំជាគណៈកម្មការនិងក្រុមការងារតាមការចាំបាច់ដើម្បីចូលរួមដោះស្រាយឱ្យបានទាន់ពេលវេលាលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ជាពិសេស ចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព ព្រមទាំងបន្តសហការអនុវត្តអនុក្រឹត្យលេខ៣៨អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលតួនាទីនិងភារកិច្ចរបស់ក្រសួងបរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសមត្ថកិច្ចនិងការគ្រប់គ្រងក្នុងក្របខ័ណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការឆ្នាំ២០១៦នេះ។

## IV- ទិសដៅអនុវត្តបន្ត

### **១ ផ្នែកដាំដុះ** :

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវវស្សា និងដំណាំកសិកម្មផ្សេងទៀតឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៦

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាពសន្សំសំចៃ ដើម្បីកាត់បន្ថយផលប៉ះពាល់បង្កដោយគ្រោះរាំងស្ងួត គ្រោះខ្វះទឹកដែលអាចកើតឡើងនៅចុងរដូវ និងដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចនិងផ្តល់ក្តីសង្ឃឹមអំពីតម្លៃកៅស៊ូនៅលើទីផ្សារដែលអាចនឹងឡើងថ្លៃវិញនៅពេលអនាគត។

### **២ ផ្នែកផលិតកម្មនិងបសុព្យាបាល** :

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺជ្រូកត្រចៀកខៀវ ក៏ដូចជាជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្ត ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តាខេត្ត-រាជធានី និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣ ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណីតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង ស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាព រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២ និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

**៤ ផ្នែកជលផល** :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តតាមដាននិងសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការទប់ស្កាត់បទល្មើសនេសាទ ពិសេសក្នុងរដូវបិទនេសាទឆ្នាំ២០១៦

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៦ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្កា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

### ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិងទាន់ពេលវេលា

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ។ ទន្ទឹមនឹងនេះ ក៏បានគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយសាលាជាតិកសិកម្មព្រែកលៀប និងកំពង់ចាមឱ្យទៅជាវិទ្យាស្ថានវិញ

- បន្តរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា តាមស្មារតីនៃលិខិតលេខ១៣០៣ សជណ.សរ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

- បន្តសហការអនុវត្តអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលតួនាទី

និងភារកិច្ចរបស់ក្រសួងបរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសមត្ថកិច្ចនិងការគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងការគ្រប់គ្រងតំបន់ការពារនិងអភិរក្សព្រៃឈើនិងជលផល ជាពិសេសការផ្ទេរតំបន់ព្រៃការពារ តំបន់អភិរក្សព្រៃឈើចំនួន ១៣កន្លែង និងព្រៃផ្តល់ផលចំនួន ៥កន្លែង ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទៅក្រសួងបរិស្ថានគ្រប់គ្រង និងបានផ្ទេរតំបន់សម្បទានដីសេដ្ឋកិច្ចចំនួន ៧៣កន្លែង ពីក្រសួងបរិស្ថាន ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់គ្រងបន្ត តាមរយៈអនុក្រឹតលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៦

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ គោលការណ៍ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្ម មានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្ម មានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស ស្តង់ដារ និងការផលិតសម្រាប់ឈានទៅរកការធ្វើសមាហរណកម្មពាណិជ្ជកម្មផលិតផលកសិកម្មក្នុងបរិបទនៃសាកលភាវូបនីយកម្ម៕

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**